**មាត្រា ៣ ._** ទីតាំងគណៈកម្មការឃុំថ្មី ស្ថិតក្នុងភូមិថ្មី ។

**មាត្រា ៤ ._** រាល់បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាននិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៦០ អនក្រ.បក
## ស្តីពីការបង្កើត ឃុំតាគង់ ចំណុះស្រុក
## ម៉ាឡៃ ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ ._** ត្រូវបានបង្កើត ឃុំតាគង់ ចំណុះស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយកាត់យកភូមិសរុបអស់ចំនួន របស់ឃុំទួលពង្រ ក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២ ._** ឃុំតាគង់ មានព្រំប្រទល់ដូចជា :

-ខាងជើងទល់ នឹង ព្រំប្រទល់ឃុំនិមិត្ត ឃុំគុត្តសត និងឃុំសំរោង ស្រុកអូរជ្រៅ

-ខាងត្បូងទល់ នឹង ព្រំប្រទល់ឃុំសឿ ស្រុកមង្គលបុរី

-ខាងកើតទល់ នឹង ព្រំប្រទល់ឃុំចំណោម ស្រុកមង្គលបុរី

-ខាងលិចទល់ នឹង ព្រំប្រទល់ឃុំទួលពង្រ ស្រុកម៉ាឡៃ

www.pheakdeylaw.com

មាត្រា ៣ ._ ទីតាំងគណៈកម្មការឃុំ ស្ថិតក្នុងភូមិពោធិ៍រ៉ែល ។

មាត្រា ៤ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៦១ អនក្រ.បក
## ស្តីពីការបង្កើត ឃុំអូរបីជាន់ ចំណុះស្រុក
## អូរជ្រៅ ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

មាត្រា ១ ._ ត្រូវបានបង្កើតឃុំអូរបីជាន់ ចំណុះស្រុកអូរជ្រៅ ដោយកាត់យកភូមិសរុបចំនួន របស់ភូមិ ពោធិ៍រ៉ែល ភូមិនិមិត្ត និង ភូមិគីឡូ ក្នុងស្រុកអូរជ្រៅ និងភូមិស្ទឹងក្រោម ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ ._ ឃុំអូរបីជាន់ មានព្រំប្រទល់ដូចតទៅ :

-ខាងជើងទល់ នឹង ព្រំប្រទល់ភូមិស្ទឹងក្រោម ស្រុកស្វាយចេក

-ខាងត្បូងទល់ នឹង ព្រំប្រទល់ភូមិសូភី ភូមិនិមិត្ត ភូមិគូប និងភូមិពោធិ៍រ៉ែល ស្រុកអូរជ្រៅ

-ខាងកើតទល់ នឹង ព្រំប្រទល់ប្រទេសថៃ

www.pheakdeylaw.com